**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធានារ៉ាប់រង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់នូវវិធាន នីតិវិធី និងនិយាម សម្រាប់ការគ្រប់គ្រងនិងការត្រួតពិនិត្យសកម្មភាពធានារ៉ាប់រង សំដៅធានានូវអភិបាលកិច្ចល្អ ប្រសិទ្ធភាព ការប្រកួតប្រជែងដោយស្មើភាពនិងស្មោះត្រង់ និងការការពារផលប្រយោជន៍និងការបង្កើនទំនុកចិត្តដល់សាធារណជនក្នុងវិស័យធានារ៉ាប់រង ដោយអនុលោមតាមច្បាប់ស្តីពីការធានារ៉ាប់រង។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់សកម្មភាពធានារ៉ាប់រងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែសកម្មភាពធានារ៉ាប់រងខ្នាតតូច ដែលត្រូវចែងក្នុងអនុក្រឹត្យដោយឡែក និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**មាត្រា៣.-**

វាក្យសព្ទដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ៖

- **ប្រធានអ.ស.ហ.** សំដៅដល់ប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- **គ្រឹះស្ថានធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រង ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង និងក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង
- **ក្រុមហ៊ុនធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងក្រុមហ៊ុនធានារ៉ាប់រងបន្ត
- **អន្តរការីធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលទាំងឡាយណាដែលផ្តល់សេវាវិជ្ជាជីវៈធានារ៉ាប់រងដល់អតិថិជនក្នុងការរៀបចំកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនធានារ៉ាប់រងនិងអតិថិជន ដើម្បីទទួលបានកម្រៃពីការផ្តល់សេវានោះ។ អន្តរការីធានារ៉ាប់រង រួមមានភ្នាក់ងារធានារ៉ាប់រងនិងជើងសាធានារ៉ាប់រង

- **ភ្នាក់ងារធានារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលជួសមុខឱ្យក្រុមហ៊ុនធានារ៉ាប់រងធ្វើការណែនាំអំពីការលក់បណ្ណសន្យារ៉ាប់រង ការរៀបចំកិច្ចសន្យាធានារ៉ាប់រង ការប្រមូលបុព្វលាភ ការរៀបចំការធ្វើសំណងជាដើម ក្នុងក្របខណ្ឌកំណត់ច្បាស់លាស់នៃកិច្ចព្រមព្រៀងរវាងភ្នាក់ងារធានារ៉ាប់រងនិងក្រុមហ៊ុនធានារ៉ាប់រង ដោយទទួលកម្រៃជើងសាពីក្រុមហ៊ុនធានារ៉ាប់រងនោះ
- **ជើងសាធានារ៉ាប់រង** សំដៅដល់នីតិបុគ្គលដែលធ្វើការក្នុងគោលដៅនៃអត្ថប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រង ផ្តល់សេវាប្រឹក្សា ផ្តល់ព័ត៌មានទាក់ទងនឹងប្រភេទធានារ៉ាប់រង លក្ខខណ្ឌ និងបុព្វលាភនៃកិច្ចសន្យាធានារ៉ាប់រង ធ្វើការចរចា និងរៀបចំកិច្ចសន្យាធានារ៉ាប់រងរវាងអ្នកស្នើសុំការធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រង និងលក់បណ្ណសន្យារ៉ាប់រង ដោយទទួលកម្រៃជើងសាពីក្រុមហ៊ុនធានារ៉ាប់រងឬកម្រៃប្រឹក្សាពីអតិថិជន
- **ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង** សំដៅដល់នីតិបុគ្គលឯករាជ្យពីក្រុមហ៊ុនធានារ៉ាប់រង ដែលមានភារកិច្ចត្រួតពិនិត្យ ផ្ទៀងផ្ទាត់ វាយតម្លៃការខូចខាតពេលមានហានិភ័យធានារ៉ាប់រងកើតឡើង និងកំណត់ចេញនូវឯកសារសម្រាប់ជាមូលដ្ឋានឱ្យក្រុមហ៊ុនធានារ៉ាប់រងដោះស្រាយទូទាត់សំណង។ ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងធ្វើសកម្មភាពដោយទទួលថ្លៃឈ្នួលពិនិត្យ ពីក្រុមហ៊ុនធានារ៉ាប់រង
- **ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនវិជ្ជាជីវៈដែលមានជំនាញវិភាគនិងគណនាហានិភ័យធានារ៉ាប់រង ដើម្បីកំណត់អត្រាបុព្វលាភធានារ៉ាប់រង
- **ម្ចាស់បណ្ណសន្យារ៉ាប់រង** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានសិទ្ធិស្របច្បាប់លើបណ្ណសន្យារ៉ាប់រង។ ក្នុងករណីមួយចំនួន ម្ចាស់បណ្ណសន្យារ៉ាប់រងអាចជាអ្នកទទួលផលផងនិងអាចជាអ្នកត្រូវបានធានារ៉ាប់រងផងនៃបណ្ណសន្យារ៉ាប់រង
- **ការធានារ៉ាប់រងបន្ត** សំដៅដល់ប្រតិបត្តិការធានារ៉ាប់រងដែលក្រុមហ៊ុនធានារ៉ាប់រងដើមត្រូវបានធានា-រ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងផ្សេងទៀតដែលជាក្រុមហ៊ុនធានារ៉ាប់រងបន្ត នូវហានិភ័យមួយផ្នែកឬទាំងស្រុង ដែលខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រង
- **កិច្ចសន្យាធានារ៉ាប់រងស្ទួន** សំដៅដល់កិច្ចសន្យាដែលអ្នកត្រូវបានធានារ៉ាប់រងបានចុះកិច្ចសន្យាធានារ៉ាប់រងលើសពីមួយ ជាមួយក្រុមហ៊ុនធានារ៉ាប់រងផ្សេងគ្នាក្នុងគោលដៅធានាលើកម្មវត្ថុតែមួយ ដែលនៅក្រោមលក្ខខណ្ឌដូចគ្នា និងក្រោមព្រឹត្តិការណ៍ធានាដូចគ្នា
- **កិច្ចសន្យាសហធានារ៉ាប់រង** សំដៅដល់កិច្ចសន្យាដែលក្រុមហ៊ុនធានារ៉ាប់រងទូទៅលើសពីមួយសហការគ្នាធានាលើហានិភ័យតែមួយ

- **អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង** សំដៅដល់អ្នកជំនាញវិភាគនិងគណនាហានិភ័យធានារ៉ាប់រងជាក់លាក់ណាមួយដើម្បីកំណត់អត្រាបុព្វលាភធានារ៉ាប់រង
- **នីតិបុគ្គលប្រតិស្រុត** សំដៅដល់នីតិបុគ្គលដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤.-**

និយ័តករធានារ៉ាប់រងកម្ពុជា ដែលសរសេរជាអក្សរកាត់ថា "**ន.ធ.ក.**" មានសមត្ថកិច្ចក្នុងការស្នើនូវបទប្បញ្ញត្តិសម្រាប់គ្រប់គ្រងនិងត្រួតពិនិត្យការធ្វើអាជីវកម្មធានារ៉ាប់រង ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការធានារ៉ាប់រងនិងអនុក្រឹត្យនេះ ជូនដល់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដើម្បីអនុម័តនិងដាក់ឱ្យអនុវត្ត។

**ន.ធ.ក.** មានសមត្ថកិច្ចក្នុងការគ្រប់គ្រងនិងការត្រួតពិនិត្យការធ្វើអាជីវកម្មធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៥.-**

**ន.ធ.ក.** មានសមត្ថកិច្ចបង្កើតនិងគ្រប់គ្រងមូលនិធិអភិវឌ្ឍវិស័យធានារ៉ាប់រងដើម្បីជំរុញការអភិវឌ្ឍ ការទ្រទ្រង់ និងការលើកកម្ពស់ការផ្សព្វផ្សាយអំពីសារប្រយោជន៍នៃការធានារ៉ាប់រងដល់សាធារណជន។

## ជំពូកទី៣
## កិច្ចសន្យាធានារ៉ាប់រង

**មាត្រា៦.-**

ការធានារ៉ាប់រងដែលមានអត្ថប្រយោជន៍ដល់រូបវន្តបុគ្គលឬនីតិបុគ្គលជាអ្នកត្រូវបានធានារ៉ាប់រងចំពោះហានិភ័យទាំងឡាយទោះបីជាប្រភេទធានារ៉ាប់រងអាយុជីវិតក្តីឬជាប្រភេទធានារ៉ាប់រងទូទៅក្តីត្រូវតែជាការចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលមានអាជ្ញាបណ្ណឱ្យធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ផ្នែកទី១
### បែបបទទូទៅ
### ១. លក្ខខណ្ឌ សុពលភាព និងនីតិវិធីនៃការបង្កើតកិច្ចសន្យាធានារ៉ាប់រង

**មាត្រា៧.-**

កិច្ចសន្យាធានារ៉ាប់រងសំដៅដល់កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយក្រុមហ៊ុន

ធានារ៉ាប់រង និងអ្នកត្រូវបានធានារ៉ាប់រង ដែលតាមរយៈនោះ ក្រុមហ៊ុនធានារ៉ាប់រងព្រមទទួលនូវហានិភ័យជាក់លាក់ណាមួយដោយទទួលមកវិញនូវការបង់បុព្វលាភធានារ៉ាប់រងពីអ្នកត្រូវបានធានារ៉ាប់រង។

កិច្ចសន្យាធានារ៉ាប់រង មានធាតុជាអប្បបរមាដូចខាងក្រោម៖

១. បណ្ណសន្យារ៉ាប់រងឬកំណត់សំអាង។

២. វិញ្ញាបនបត្រធានារ៉ាប់រង។

**មាត្រា៨.-**

បណ្ណសន្យារ៉ាប់រង ជាឯកសារមួយនៃកិច្ចសន្យាធានារ៉ាប់រងជាក់លាក់ដើម្បីប្រើប្រាស់ជាភស្តុតាងសម្រាប់បង្កើតកិច្ចសន្យាធានារ៉ាប់រង។ បណ្ណសន្យារ៉ាប់រងត្រូវចុះហត្ថលេខា ឬប្រថាប់ត្រាដោយក្រុមហ៊ុនធានារ៉ាប់រង ឬដោយអន្តរការីធានារ៉ាប់រងដែលមានសិទ្ធិលក់ផលិតផលធានារ៉ាប់រង។

**មាត្រា៩.-**

បណ្ណសន្យារ៉ាប់រង ត្រូវកំណត់លក្ខខណ្ឌទូទៅនិង/ឬលក្ខខណ្ឌពិសេសនៃកិច្ចសន្យាធានារ៉ាប់រងដូចខាងក្រោម៖

១. លក្ខខណ្ឌទូទៅនៃកិច្ចសន្យាធានារ៉ាប់រងមានកំណត់ប្រភេទហានិភ័យដែលត្រូវបានធានារ៉ាប់រង និងប្រភេទហានិភ័យដែលមិនត្រូវបានធានារ៉ាប់រង។

២. លក្ខខណ្ឌពិសេសនៃកិច្ចសន្យាធានារ៉ាប់រង មានកំណត់សំណូមពរពិសេសដោយឡែករបស់អ្នកត្រូវបានធានារ៉ាប់រង តាមការប្រកាសរបស់អ្នកត្រូវបានធានារ៉ាប់រងនៅក្នុងពាក្យស្នើសុំធានារ៉ាប់រង។

និទ្ទេសអប្បបរមានៃបណ្ណសន្យារ៉ាប់រង ត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

**មាត្រា១០.-**

កំណត់សំអាង ជាឯកសារបណ្ដោះអាសន្ន ដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងឬអន្តរការីធានារ៉ាប់រងដែលមានសិទ្ធិលក់បណ្ណសន្យារ៉ាប់រង ជំនួសបណ្ណសន្យារ៉ាប់រងនៅក្នុងករណីចាំបាច់និងបន្ទាន់ ដែលក្រុមហ៊ុនធានារ៉ាប់រងឬអន្តរការីធានារ៉ាប់រងដែលមានសិទ្ធិលក់ មិនអាចចុះកិច្ចសន្យានិងចេញបណ្ណសន្យារ៉ាប់រងបាន។

កំណត់សំអាង ត្រូវចុះហត្ថលេខាដោយក្រុមហ៊ុនធានារ៉ាប់រងឬអន្តរការីធានារ៉ាប់រងដែលមានសិទ្ធិលក់បណ្ណសន្យារ៉ាប់រងនិងអ្នកត្រូវបានធានារ៉ាប់រង មុនពេលប្រគល់ជូនអ្នកត្រូវបានធានារ៉ាប់រង។

កំណត់សំអាងត្រូវបញ្ជាក់និទ្ទេសអប្បបរមាដូចខាងក្រោម៖

- អត្តលេខនៃពាក្យស្នើសុំនិងអ្នកស្នើសុំ

- សេចក្ដីសង្ខេបនៃផលិតផលធានារ៉ាប់រង
- កម្មវត្ថុនិងសុពលភាពនៃកំណត់សំអាង
- ថិរវេលានៃកំណត់សំអាង
- អត្ថប្រយោជន៍ដែលត្រូវទទួលបានក្នុងករណីមានហានិភ័យកើតឡើងក្នុងអំឡុងពេលបណ្ដោះអាសន្ន។

**មាត្រា១១.-**

វិញ្ញាបនបត្រធានារ៉ាប់រងឬសេចក្ដីសង្ខេបនៃបណ្ណសន្យារ៉ាប់រង ត្រូវបញ្ជាក់អំពី៖

- គោត្តនាមនិងនាម និងអាសយដ្ឋានរបស់ភាគីនៃកិច្ចសន្យា
- បុគ្គលឬវត្ថុដែលត្រូវបានធានា
- ប្រភេទហានិភ័យដែលត្រូវបានធានារ៉ាប់រង
- ពេលវេលាចាប់ផ្ដើមនិងទីកន្លែងនៃហានិភ័យដែលត្រូវបានធានារ៉ាប់រង
- ចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង
- បុព្វលាភធានារ៉ាប់រងដែលត្រូវបង់និងរបៀបបង់បុព្វលាភធានារ៉ាប់រង
- របៀបនិងលក្ខខណ្ឌមួយចំនួននៃសេចក្ដីប្រកាសគ្រោះថ្នាក់
- រយៈពេលនៃកិច្ចសន្យានិងរយៈពេលនៃការធានារ៉ាប់រង
- លក្ខខណ្ឌទាំងឡាយដែលកំណត់មោឃភាពនិងការបាត់បង់សិទ្ធិព្រមទាំងលក្ខខណ្ឌដែលអនុញ្ញាតឱ្យគូភាគីនីមួយៗបញ្ចប់កិច្ចសន្យាបានមុនកាលកំណត់។

ក្រៅពីចំណុចដែលមានកំណត់ខាងលើ គូភាគីអាចដាក់បន្ថែមនូវចំណុចផ្សេងៗទៀតបានដោយមានការព្រមព្រៀងគ្នាជាមុន។

**មាត្រា១២.-**

កិច្ចសន្យាធានារ៉ាប់រង ត្រូវបញ្ជាក់ពីកម្មវត្ថុនៃការធានារ៉ាប់រង មានជាអាទិ៍ទ្រព្យសម្បត្តិ រូបរាងកាយ និងអាយុជីវិត។

**មាត្រា១៣.-**

ភាគីនៃកិច្ចសន្យាធានារ៉ាប់រងរួមមាន៖

- ក្រុមហ៊ុនធានារ៉ាប់រង និង
- ម្ចាស់បណ្ណសន្យារ៉ាប់រងឬអ្នកត្រូវបានធានារ៉ាប់រង។

ម្ចាស់បណ្ណសន្យារ៉ាប់រងឬអ្នកត្រូវបានធានារ៉ាប់រង ដែលអាចចុះកិច្ចសន្យាធានារ៉ាប់រងបានត្រូវតែជានីតិជន ឬអនីតិជនដែលទទួលអត្តាធីនភាពឬនីតិបុគ្គល។

**មាត្រា១៤.-**

ការចុះកិច្ចសន្យាធានារ៉ាប់រងត្រូវធ្វើឡើងដោយឆន្ទៈ សេរី និងពិតប្រាកដ អនុលោមទៅតាមបទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៥.-**

កិច្ចសន្យាធានារ៉ាប់រងនិងឯកសារដែលផ្តល់ឱ្យម្ចាស់បណ្ណសន្យារ៉ាប់រងឬអ្នកត្រូវបានធានារ៉ាប់រង ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយយកភាសាខ្មែរជាគោល។

**មាត្រា១៦.-**

ដើម្បីចុះកិច្ចសន្យាធានារ៉ាប់រង អ្នកដែលមានបំណងចុះកិច្ចសន្យាធានារ៉ាប់រង ត្រូវដាក់ពាក្យស្នើសុំធានារ៉ាប់រងទៅក្រុមហ៊ុនធានារ៉ាប់រងដោយផ្ទាល់ឬតាមរយៈអន្តរការីធានារ៉ាប់រង ក្នុងទម្រង់លិខិតអនុសិដ្ឋដោយមានហត្ថលេខានិង/ឬ ស្នាមមេដៃ។ ផ្អែកលើពាក្យស្នើសុំឬប្រតិវេទន៍នេះ ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើការសិក្សានិងត្រួតពិនិត្យ។ ក្នុងករណីដែលក្រុមហ៊ុនធានារ៉ាប់រងឯកភាពលើពាក្យស្នើសុំ ក្រុមហ៊ុនធានារ៉ាប់រងអាចចេញបណ្ណសន្យារ៉ាប់រងជូនបាន។

នៅក្នុងករណីចាំបាច់ឬបន្ទាន់ណាមួយដែលបណ្ណសន្យារ៉ាប់រងមិនទាន់ត្រូវបានចេញ ការធានារ៉ាប់រងអាចប្រព្រឹត្តទៅបានដោយការប្រើប្រាស់ “កំណត់សំអាង” ជាបណ្តោះអាសន្ន។

**មាត្រា១៧.-**

ផលិតផលធានារ៉ាប់រង គឺជាកិច្ចសន្យាធានារ៉ាប់រងដែលដាក់លក់លើទីផ្សារធានារ៉ាប់រង។ គំរូកិច្ចសន្យាធានារ៉ាប់រងទាំងអស់ដែលហៅថា ផលិតផលធានារ៉ាប់រង ត្រូវមានការអនុញ្ញាតពី **ន.ធ.ក.** មុននឹងដាក់លក់នៅលើទីផ្សារធានារ៉ាប់រង។

## ២. អានុភាពនៃការធានារ៉ាប់រង

**មាត្រា១៨.-**

ការធានារ៉ាប់រងមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទ ដែលអ្នកត្រូវបានធានារ៉ាប់រងបានបង់បុព្វលាភធានារ៉ាប់រងតាមកាលកំណត់ក្នុងកិច្ចសន្យាធានារ៉ាប់រង។



៥ ថ្ងៃ

ក្នុងករណីក្រុមហ៊ុនធានារ៉ាប់រងមិនបានកំណត់ពីកាលបរិច្ឆេទអានុភាពនៃការធានាឬកាលបរិច្ឆេទបង់បុព្វលាភធានារ៉ាប់រងនៅក្នុងឯកសារណាមួយនៃកិច្ចសន្យាធានារ៉ាប់រង កាលបរិច្ឆេទដែលអ្នកត្រូវបានធានារ៉ាប់រងបានបង់បុព្វលាភធានារ៉ាប់រងត្រូវសន្មតថាជាកាលបរិច្ឆេទនៃអានុភាពការធានារ៉ាប់រង។

អ្នកត្រូវបានធានារ៉ាប់រងមានសិទ្ធិប្រើប្រាស់កាលបរិច្ឆេទនៃបង្កាន់ដៃបង់បុព្វលាភធានារ៉ាប់រង ជាភស្តុតាងបញ្ជាក់ពីកាលបរិច្ឆេទនៃអានុភាពការធានារ៉ាប់រង។

## ៣. ភារកិច្ចរបស់អ្នកត្រូវបានធានារ៉ាប់រង

**មាត្រា១៩.-**

អ្នកត្រូវបានធានារ៉ាប់រង មានកាតព្វកិច្ចដូចតទៅ៖

១. ផ្តល់ព័ត៌មានផ្ទាល់មាត់និង/ឬឯកសារលាយលក្ខណ៍អក្សរដោយពិស្តារ ច្បាស់លាស់ប្រកបដោយភាពស្មោះត្រង់ ទៅឱ្យក្រុមហ៊ុនធានារ៉ាប់រងឬអន្តរការីធានារ៉ាប់រង។

២. បង់បុព្វលាភធានារ៉ាប់រង ដោយអនុលោមទៅតាមតារាងនៃការបង់បុព្វលាភធានារ៉ាប់រងរបស់អ្នកត្រូវបានធានារ៉ាប់រងនីមួយៗ។ ការបង់បុព្វលាភធានារ៉ាប់រង គឺជាកាតព្វកិច្ចចម្បងរបស់អ្នកត្រូវបានធានារ៉ាប់រង។ នៅក្នុងការបង់បុព្វលាភធានារ៉ាប់រងនេះ អ្នកត្រូវបានធានារ៉ាប់រងមានសិទ្ធិចរចាជាមួយក្រុមហ៊ុនធានា-រ៉ាប់រង ដើម្បីសម្រេចយកការបង់បុព្វលាភធានារ៉ាប់រងសរុបឬបង់ជាដំណាក់កាល។

៣. អ្នកត្រូវបានធានារ៉ាប់រងឬអ្នកទទួលផល ដែលទទួលរងនូវការបាត់បង់ឬការខូចខាតស្របតាមកិច្ចសន្យាធានារ៉ាប់រង រួមមានការបាត់បង់ ឬការខូចខាតទ្រព្យសម្បត្តិ និង/ឬ ការរងរបួសលើរូបរាងកាយ ឬពិការភាព ឬទទួលមរណភាព ត្រូវជូនដំណឹងជាបន្ទាន់ តាមគ្រប់មធ្យោបាយទៅក្រុមហ៊ុនធានារ៉ាប់រងនៅពេលមានហានិភ័យធានារ៉ាប់រងកើតឡើង។

៤. អ្នកត្រូវបានធានារ៉ាប់រងឬអ្នកទទួលផល ត្រូវផ្តល់ភស្តុតាងផ្ទាល់មាត់និង/ឬលាយលក្ខណ៍អក្សរពាក់ព័ន្ធនឹងការកើតឡើងនូវហានិភ័យធានារ៉ាប់រង ក្នុងអំឡុងពេលសមរម្យមួយ ដូចមានចែងក្នុងកិច្ចសន្យាធានារ៉ាប់រងទៅឱ្យក្រុមហ៊ុនធានារ៉ាប់រង ដើម្បីឱ្យក្រុមហ៊ុនធានារ៉ាប់រងប្រើប្រាស់ជាមូលដ្ឋានក្នុងការសិក្សាវាយតម្លៃមុននឹងកំណត់និងទូទាត់សំណង។ ការយឺតយូរក្នុងការផ្តល់ភស្តុតាងផ្ទាល់មាត់និង/ឬជាលាយលក្ខណ៍អក្សររបស់អ្នកត្រូវបានធានារ៉ាប់រង គឺជាមូលហេតុសមរម្យដែលក្រុមហ៊ុនធានារ៉ាប់រងអាចពន្យារពេលក្នុងការចាប់ផ្តើមនីតិវិធីកំណត់និងទូទាត់សំណងធានារ៉ាប់រង។

## ៤_ ភាតព្វកិច្ចរបស់ក្រុមហ៊ុនធានារ៉ាប់រង

**មាត្រា២០ _**

ក្រុមហ៊ុនធានារ៉ាប់រង មានកាតព្វកិច្ចដូចតទៅៈ

១_ ពន្យល់អ្នកដែលមានបំណងចុះកិច្ចសន្យាធានារ៉ាប់រងឱ្យបានយល់ច្បាស់អំពីលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រងនិងខ្លឹមសារនៃបណ្ណសន្យារ៉ាប់រង ឬកំណត់សំអាងដែលភ្ជាប់ជាមួយនឹងវិញ្ញាបនបត្រធានារ៉ាប់រង ឬសេចក្តីសង្ខេបនៃបណ្ណសន្យារ៉ាប់រង និង/ឬ ឯកសារពាក់ព័ន្ធផ្សេងៗ ប្រកបដោយភាពស្មោះត្រង់។

២_ ចេញបណ្ណសន្យារ៉ាប់រងឬចេញកំណត់សំអាង វិញ្ញាបនបត្រធានារ៉ាប់រងឬសេចក្តីសង្ខេបនៃបណ្ណសន្យារ៉ាប់រង និង/ឬឯកសារពាក់ព័ន្ធផ្សេងៗទៀតទៅឱ្យអ្នកស្នើសុំធានារ៉ាប់រងនៅពេលក្រុមហ៊ុនបានទទួលបុព្វលាភធានារ៉ាប់រង។

៣_ ធ្វើសំណងដល់ការខូចខាតឬការបាត់បង់ដែលជាកម្មវត្ថុនៃការធានារ៉ាប់រង នៅពេលហានិភ័យកើតឡើង ឬតាមការកំណត់នៃកិច្ចសន្យាធានារ៉ាប់រង។ ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងត្រឹមត្រូវតាមការកំណត់អត្ថប្រយោជន៍ឬចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រង តាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យាធានារ៉ាប់រង។ ក្រុមហ៊ុនធានារ៉ាប់រងមានកាតព្វកិច្ចជួយដល់អ្នកត្រូវបានធានារ៉ាប់រងឬអ្នកទទួលផលក្នុងការប្រមូលព័ត៌មាន ភស្តុតាង និងផ្តល់ការណែនាំក្នុងគោលដៅកាត់បន្ថយនូវកម្រិតព្យសនកម្ម នៅពេលទទួលបានការជូនដំណឹងអំពីហានិភ័យដែលកើតមានចំពោះកម្មវត្ថុនៃកិច្ចសន្យាធានារ៉ាប់រង។

៤_ ជូនដំណឹងដល់អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផល ឬសម្ព័ន្ធញាតិ ឬម្ចាស់បណ្ណសន្យារ៉ាប់រងនៅពេលបានទទួលដំណឹងមរណភាពឬវិបល្លាសស្មារតីរបស់អ្នកត្រូវបានធានារ៉ាប់រង។

៥_ រក្សាការសម្ងាត់ រាល់ព័ត៌មានអំពីអ្នកស្នើសុំធានារ៉ាប់រងឬអ្នកត្រូវបានធានារ៉ាប់រង។

៦_ បញ្ជូនបុគ្គលិកជំនាញវាយតម្លៃហានិភ័យ ឬជួលក្រុមហ៊ុនវាយតម្លៃហានិភ័យដែលមានអាជ្ញាបណ្ណឱ្យធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះសិក្សាវាយតម្លៃហានិភ័យដែលបានកើតឡើងហើយការចំណាយឬថ្លៃឈ្នួលសិក្សាវាយតម្លៃជាបន្ទុករបស់ក្រុមហ៊ុនធានារ៉ាប់រង។ ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងឬអ្នកទទួលផលមិនពេញចិត្តលើលទ្ធផលនៃការវាយតម្លៃ អ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលមានសិទ្ធិធ្វើបណ្តឹងមក**គ.ធ.ក.**។

៧. ចាប់ផ្តើមនីតិវិធីដោះស្រាយសំណងជាបន្ទាន់ បន្ទាប់ពីទទួលបានពាក្យស្នើសុំទាមទារសំណងជាប្រាក់និង/ឬវត្ថុទៅឱ្យអ្នកត្រូវបានធានារ៉ាប់រងតាមពេលវេលាកំណត់ តាមទំហំនៃការខូចខាតជាក់ស្តែងនិងតាមទឹកប្រាក់ធានារ៉ាប់រង។ គោលការណ៍ណែនាំស្តីពីនីតិវិធីដោះស្រាយសំណង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

## ៥. ការកែប្រែកិច្ចសន្យាធានារ៉ាប់រង

**មាត្រា២១.-**

គូភាគីនៃកិច្ចសន្យា មានសិទ្ធិស្នើសុំកែប្រែកិច្ចសន្យាធានារ៉ាប់រង។

ការកែប្រែកិច្ចសន្យា មានន័យថាជាការកែប្រែលក្ខខណ្ឌទាំងឡាយនៃកិច្ចសន្យាធានារ៉ាប់រង។

**មាត្រា២២.-**

កិច្ចសន្យាធានារ៉ាប់រងអាចត្រូវបានកែប្រែ អាស្រ័យតាមការព្រមព្រៀងរបស់គូភាគីនៃកិច្ចសន្យាធានារ៉ាប់រង ដោយអនុលោមតាមលក្ខខណ្ឌនៃផលិតផលធានារ៉ាប់រង។

**មាត្រា២៣.-**

ការកែប្រែណាមួយចំពោះកិច្ចសន្យាធានារ៉ាប់រងនឹងមានសុពលភាព នៅពេលដែលក្រុមហ៊ុនទទួលយកការកែប្រែ ហើយការកែប្រែនោះមានប្រសិទ្ធភាពចាប់ពីកាលបរិច្ឆេទដែលបានឯកភាពដោយគូភាគីនៃកិច្ចសន្យា។ កិច្ចសន្យាធានារ៉ាប់រងបន្ថែមនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

## ៦. ការបន្តកិច្ចសន្យាធានារ៉ាប់រង

**មាត្រា២៤.-**

គូភាគីនៃកិច្ចសន្យា មានសិទ្ធិបន្តកិច្ចសន្យាធានារ៉ាប់រងបន្ទាប់ពីកិច្ចសន្យាធានារ៉ាប់រងផុតកាលបរិច្ឆេទ។ ការបន្តកិច្ចសន្យាធានារ៉ាប់រង ជាការបន្តសុពលភាពនៃកិច្ចសន្យាធានារ៉ាប់រងនិងអានុភាពនៃការធានារ៉ាប់រង។ នីតិវិធីនៃការបន្តកិច្ចសន្យាធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

## ៧. ការផ្អាកកិច្ចសន្យាធានារ៉ាប់រង

**មាត្រា២៥.-**

គូភាគីនៃកិច្ចសន្យា មានសិទ្ធិផ្អាកកិច្ចសន្យាធានារ៉ាប់រង។ ការស្នើសុំផ្អាកកិច្ចសន្យាធានារ៉ាប់រង ជាការផ្អាកមិនអនុវត្តកិច្ចសន្យាធានារ៉ាប់រង ហើយនឹងបន្តកិច្ចសន្យាដោយរក្សានូវលក្ខខណ្ឌទាំងឡាយនៃកិច្ចសន្យាធានារ៉ាប់រង

និងអត្រាបុព្វលាភធានារ៉ាប់រងដដែល។

ការផ្អាកកិច្ចសន្យាធានារ៉ាប់រងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរនិងត្រូវមានការឯកភាពរវាងគូភាគីនៃកិច្ចសន្យា។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្អាកកិច្ចសន្យាធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

## ៨- ការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង

**មាត្រា២៦.-**

គូភាគីនៃកិច្ចសន្យាធានារ៉ាប់រង មានសិទ្ធិបញ្ចប់កិច្ចសន្យាមុនកាលកំណត់។

លក្ខខណ្ឌនិងនីតិវិធីនៃការបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

## ៩- មោឃភាពនៃកិច្ចសន្យាធានារ៉ាប់រង

**មាត្រា២៧.-**

កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើកិច្ចសន្យានោះផ្ទុយនឹងច្បាប់និងបទប្បញ្ញត្តិជាធរមាន និង/ឬសណ្តាប់ធ្នាប់សាធារណៈ និងទំនៀមទម្លាប់ល្អ។

## ១០- ការលុបចោលនៃកិច្ចសន្យាធានារ៉ាប់រង

**មាត្រា២៨.-**

កិច្ចសន្យាធានារ៉ាប់រងនឹងត្រូវបានលុបចោល ប្រសិនបើម្ចាស់បណ្ណសន្យារ៉ាប់រងឬអ្នកត្រូវបានធានារ៉ាប់រងត្រូវបានរកឃើញថាបានលាក់លៀមព័ត៌មានឬធ្វើប្រតិវេទន៍ខុសដោយចេតនា ដែលបណ្តាលឱ្យមានការផ្លាស់ប្តូរឬកែប្រែលក្ខខណ្ឌនៃកិច្ចសន្យា។

**មាត្រា២៩.-**

គូភាគីនៃកិច្ចសន្យាធានារ៉ាប់រង មានសិទ្ធិទាមទារសំណងចំពោះព្យសនកម្មដែលគូភាគីបង្កឡើងឱ្យមានវិការៈនៃការព្រមព្រៀង។

## ១១- អាជ្ញាយុកាលនៃបណ្តឹងពាក់ព័ន្ធនឹងកិច្ចសន្យាធានារ៉ាប់រង

**មាត្រា៣០.-**

បណ្តឹងតវ៉ាដែលពាក់ព័ន្ធនឹងកិច្ចសន្យាធានារ៉ាប់រងទូទៅមានអាជ្ញាយុកាល៥(ប្រាំ)ឆ្នាំ បន្ទាប់ពីថ្ងៃដែលភាគីណាមួយមិនអនុវត្តតាមលក្ខខណ្ឌនៃកិច្ចសន្យាធានារ៉ាប់រង។ ករណីបណ្តឹងតវ៉ាដែលពាក់ព័ន្ធនឹងកិច្ចសន្យា

ធានារ៉ាប់រងអាយុជីវិតមានអាជ្ញាយុកាល១៥(ដប់ប្រាំ)ឆ្នាំ បន្ទាប់ពីថ្ងៃដែលអ្នកត្រូវបានធានារ៉ាប់រងទទួលមរណភាព។ ចំពោះករណីកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតបន្ថែមដែលគ្របដណ្តប់លើហានិភ័យរូបរាងកាយ ឬសុខភាព អាជ្ញាយុកាលនៃបណ្តឹងមានរយៈពេល ៥(ប្រាំ)ឆ្នាំ បន្ទាប់ពីហានិភ័យទាំងនោះកើតឡើង។

អាជ្ញាយុកាលនៃបណ្តឹងនេះ មិនអនុវត្តចំពោះបណ្តឹងទាមទារសំណងទេ។

## ១២_ សុពលភាពនៃការទាមទារសំណង

**មាត្រា៣១ ._**

គូភាគីនៃកិច្ចសន្យាធានារ៉ាប់រងទូទៅមានសិទ្ធិកំណត់រយៈពេលសុពលភាពនៃការទាមទារសំណងក្រោយពេលផុតកាលបរិច្ឆេទនៃសុពលភាពកិច្ចសន្យាធានារ៉ាប់រងទូទៅ ប៉ុន្តែរយៈពេលនៃសុពលភាពនោះ មិនអាចតិចជាង៥(ប្រាំ)ឆ្នាំ នោះឡើយ បន្ទាប់ពីថ្ងៃផុតកាលបរិច្ឆេទនៃសុពលភាពកិច្ចសន្យាធានារ៉ាប់រងនោះ។

សម្រាប់កិច្ចសន្យាធានារ៉ាប់រងអាយុជីវិត សុពលភាពនៃការទាមទារសំណងក្រោយពេលកិច្ចសន្យាធានារ៉ាប់រងផុតសុពលភាព មិនអាចតិចជាង១៥(ដប់ប្រាំ)ឆ្នាំនោះឡើយ បន្ទាប់ពីថ្ងៃផុតកាលបរិច្ឆេទនៃសុពលភាពកិច្ចសន្យាធានារ៉ាប់រងនោះ។

សុពលភាពនៃការទាមទារសំណងខាងលើនេះ អនុវត្តបានតែក្នុងករណីដែលអ្នកត្រូវបានធានារ៉ាប់រង ឬអ្នកទទួលផលមិនបានដឹងអំពីការកើតឡើងនូវហានិភ័យចំពោះកម្មវត្ថុនៃបណ្ណសន្យារ៉ាប់រងក្នុងអំឡុងពេលដែលកិច្ចសន្យាធានារ៉ាប់រងមានសុពលភាពតែប៉ុណ្ណោះ។

**មាត្រា៣២ ._**

ក្នុងករណីក្រុមហ៊ុនធានារ៉ាប់រងទទួលបានការទាមទារសំណង ប៉ុន្តែរកពុំឃើញអ្នកត្រូវបានធានារ៉ាប់រងដើម្បីទូទាត់សំណង ក្រុមហ៊ុនធានារ៉ាប់រងមានកាតព្វកិច្ចស្វែងរកអ្នកត្រូវបានធានារ៉ាប់រងឬអ្នកទទួលផលពីកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតឱ្យអស់ពីលទ្ធភាព ក្នុងរយៈពេល១០(ដប់)ឆ្នាំ ចាប់ពីថ្ងៃដែលក្រុមហ៊ុនធានារ៉ាប់រងបានកំណត់ចេញទឹកប្រាក់សំណង។ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងរកពុំឃើញអ្នកត្រូវបានធានារ៉ាប់រងបន្ទាប់ពីរយៈពេលខាងលើនេះ ក្រុមហ៊ុនធានារ៉ាប់រងត្រូវបង្វិលទឹកប្រាក់ធានារ៉ាប់រងចូលមូលនិធិអភិវឌ្ឍវិស័យធានារ៉ាប់រង។

**មាត្រា៣៣ ._**

ក្នុងករណីដែលមានហានិភ័យធានារ៉ាប់រងកើតឡើង ហើយពុំមានអ្នកទាមទារសំណងធានារ៉ាប់រងក្នុងរយៈពេល៧ (ប្រាំពីរ)ឆ្នាំ គិតចាប់ពីថ្ងៃដែលមានហានិភ័យកើតឡើង ក្រុមហ៊ុនត្រូវបង្វិលទឹកប្រាក់ធានារ៉ាប់រងចូលមូលនិធិអភិវឌ្ឍវិស័យធានារ៉ាប់រង។

## ផ្នែកទី២
## ការធានារ៉ាប់រងទូទៅ

**មាត្រា៣៤.-**

ការធានារ៉ាប់រងទូទៅ ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រងនិងក្រុមហ៊ុនធានារ៉ាប់រង ដែលនៅក្នុងនោះការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើងដើម្បីធានាហានិភ័យលើទ្រព្យសម្បត្តិ ភារៈទទួលខុសត្រូវ និងសុខភាព។ ប្រភេទផលិតផលធានារ៉ាប់រងទូទៅ រួមមានការធានារ៉ាប់រងទ្រព្យសម្បត្តិ ការធានារ៉ាប់រងភារៈទទួលខុសត្រូវ និងការធានារ៉ាប់រងសុខភាព។

**មាត្រា៣៥.-**

នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងបានធ្វើសំណងរួចហើយ អ្នកត្រូវបានធានារ៉ាប់រងត្រូវផ្ទេរសិទ្ធិឧបាទេសកម្មបណ្តឹងទៅឱ្យក្រុមហ៊ុនធានារ៉ាប់រង ក្នុងការប្តឹងតទល់ជាមួយនឹងតតិយជនដែលបានបង្កឱ្យមានការខូចខាត ដើម្បីទាមទារមកវិញនូវទឹកប្រាក់ស្មើនឹងចំនួនដែលបានធ្វើសំណងនោះ។ ប៉ុន្តែក្រុមហ៊ុនធានារ៉ាប់រងមិនអាចប្តឹងទាមទារសំណងចំពោះហានិភ័យដែលបង្កឡើងដោយអចេតនាពីបច្ឆាញាតិ បុព្វញាតិ ញាតិពន្ធ អ្នកគ្រប់គ្រង និងកម្មករនិយោជិតដែលរស់នៅធម្មតាក្នុងលំនៅឋានរបស់អ្នកត្រូវបានធានារ៉ាប់រងនោះទេ លើកលែងតែករណីដែលមានភស្តុតាងបញ្ជាក់ថា មានការប្រព្រឹត្តកំហុសធ្ងន់ដោយចេតនាដោយជនណាម្នាក់ក្នុងចំណោមជនទាំងនោះ។

ក្នុងករណីបច្ឆាញាតិ បុព្វញាតិ ញាតិពន្ធ អ្នកគ្រប់គ្រង និងកម្មករ និយោជិតដែលរស់នៅធម្មតាក្នុងលំនៅឋានរបស់អ្នកត្រូវបានធានារ៉ាប់រងទាំងនោះមានបណ្ណសន្យារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងនៃអ្នកត្រូវបានធានារ៉ាប់រងមានសិទ្ធិប្តឹងតទល់ជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងដែលធានារ៉ាប់រងលើជនទាំងនោះ។

ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិទារសងវិញឬរួចផុតពីកាតព្វកិច្ចធ្វើសំណង ប្រសិនបើក្រុមហ៊ុនបាត់បង់សិទ្ធិឧបាទេសកម្មបណ្តឹងរបស់ខ្លួន ដោយសារទង្វើរបស់អ្នកត្រូវបានធានារ៉ាប់រង។

**មាត្រា៣៦.-**

ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រង បានចុះកិច្ចសន្យាធានារ៉ាប់រងស្ទួន អ្នកត្រូវបានធានារ៉ាប់រងទទួលបានតែសំណងដែលមានទំហំទឹកប្រាក់មិនលើសពីទំហំខូចខាត ឬបាត់បង់ជាក់ស្តែងនៃទ្រព្យសម្បត្តិ ឬថ្លៃចំណាយវេជ្ជសាស្ត្រ។

**មាត្រា៣៧.-**

ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងបានចុះកិច្ចសន្យាសហធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងនីមួយៗ ត្រូវទទួល

ខុសត្រូវធ្វើសំណងទៅតាមសមាមាត្រនៃហានិភ័យដែលបានធានា។

**មាត្រា៣៨.-**

កិច្ចសន្យាធានារ៉ាប់រងអាចត្រូវបានផ្ទេរ ក្នុងករណីទ្រព្យសម្បត្តិដែលធានាត្រូវបានលក់បន្ត ហើយកម្មសិទ្ធិករថ្មីបានជូនដំណឹងភ្លាមទៅក្រុមហ៊ុនធានារ៉ាប់រងនិងបានស្នើសុំធ្វើកិច្ចសន្យាបន្ថែម ដើម្បីផ្ទេរការធានារ៉ាប់រងនោះមកឈ្មោះរបស់ខ្លួនជាផ្លូវការ។

ក្នុងករណីដែលកម្មសិទ្ធិករចាស់ ធ្វើលិខិតអនុសិដ្ឋសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រង ក្នុងរយៈពេលយូរបំផុត ១០(ដប់)ថ្ងៃនៃថ្ងៃប្រតិទិន បន្ទាប់ពីការលក់និងកម្មសិទ្ធិករថ្មីមិនបានស្នើសុំឱ្យធ្វើកិច្ចសន្យាបន្ថែម ដើម្បីផ្ទេរកិច្ចសន្យាធានារ៉ាប់រងទេនោះ ក្រុមហ៊ុនធានារ៉ាប់រងមានកាតព្វកិច្ចបង្វិលសងវិញចំនួន៩០%(កៅសិបភាគរយ) នៃបុព្វលាភធានារ៉ាប់រងសម្រាប់ រយៈពេលដែលនៅសល់ ក្នុងករណីដែលកិច្ចសន្យាធានារ៉ាប់រងនេះមិនទាន់មានបណ្តឹងទាមទារសំណង។

កម្មសិទ្ធិករចាស់នៅតែជាប់កាតព្វកិច្ចបង់បុព្វលាភធានារ៉ាប់រងរហូតតាមកិច្ចសន្យាធានារ៉ាប់រង ប្រសិនបើមិនបានជូនដំណឹងពីការលក់បន្តនោះទៅក្រុមហ៊ុនធានារ៉ាប់រងរបស់ខ្លួនតាមរយៈលិខិតអនុសិដ្ឋឬលិខិតជូនដំណឹង ដែលត្រូវបញ្ជាក់តបវិញច្បាស់លាស់ពីការបានទទួលនោះឬមិនបានសុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រង។ ក្នុងករណីកម្មសិទ្ធិករចាស់ខកខានក្នុងការបង់បុព្វលាភ ក្រុមហ៊ុនធានារ៉ាប់រងនិងកម្មសិទ្ធិករថ្មី មានសិទ្ធិបញ្ចប់កិច្ចសន្យាធានារ៉ាប់រងនេះបាន។

**មាត្រា៣៩.-**

ក្នុងករណី អ្នកត្រូវបានធានារ៉ាប់រងជាម្ចាស់នៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការធានា ទទួលមរណភាព កាតព្វកិច្ចបង់បុព្វលាភ នឹងត្រូវធ្លាក់ទៅលើសន្តតិជនដែលទទួលទ្រព្យសម្បត្តិខាងលើនេះ។

សន្តតិជនមានកាតព្វកិច្ចដូចគ្នាទៅនឹងអ្នកត្រូវបានធានារ៉ាប់រងដែលទទួលមរណភាព។ ក្នុងលក្ខខណ្ឌនេះ សន្តតិជនមានសិទ្ធិស្នើសុំបញ្ចប់ឬផ្ទេរកិច្ចសន្យាធានារ៉ាប់រងទៅតាមឆន្ទៈ។

**មាត្រា៤០.-**

ក្នុងករណីអ្នកត្រូវបានធានារ៉ាប់រង សុំបញ្ចប់កិច្ចសន្យាធានារ៉ាប់រងទូទៅមុនកាលកំណត់ អ្នកត្រូវបានធានារ៉ាប់រង ត្រូវអនុវត្តនីតិវិធីដូចមានកំណត់ក្នុងមាត្រា២៦នៃអនុក្រឹត្យនេះ។ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងយល់ព្រមលើសំណើសុំបញ្ចប់ ក្រុមហ៊ុនធានារ៉ាប់រងត្រូវមានកាតព្វកិច្ចបង្វិលសងវិញចំនួន៩០%(កៅសិបភាគរយ) នៃបុព្វលាភធានារ៉ាប់រងសម្រាប់រយៈពេលដែលនៅសល់។

ក្នុងករណីការសុំបញ្ចប់ការធានារ៉ាប់រងក្រោយពេលក្រុមហ៊ុនបានទូទាត់សំណងរួច ក្រុមហ៊ុនធានារ៉ាប់រងមិនមានកាតព្វកិច្ចបង្វិលសងបុព្វលាភធានារ៉ាប់រងសម្រាប់រយៈពេលដែលនៅសល់វិញឡើយ។

## ផ្នែកទី៣
## ការធានារ៉ាប់រងអាយុជីវិត

**មាត្រា៤១ .-**

ការធានារ៉ាប់រងអាយុជីវិត ជាកិច្ចសន្យាធានារ៉ាប់រងដែលធ្វើឡើងរវាងអ្នកត្រូវបានធានារ៉ាប់រងនិងក្រុមហ៊ុនធានារ៉ាប់រង ដែលក្នុងនោះការបង់បុព្វលាភធានារ៉ាប់រងត្រូវធ្វើឡើង ដើម្បីធានាទៅលើការស្លាប់ឬការរស់រានមានជីវិតដោយអាចរួមបញ្ចូលការធានារ៉ាប់រងលើគ្រោះថ្នាក់បុគ្គល ជំងឺធ្ងន់ធ្ងរ ឬជំងឺទូទៅ។ ប្រភេទផលិតផលធានារ៉ាប់រងអាយុជីវិត មានដូចជា ការធានារ៉ាប់រងអាយុជីវិតមានកាលកំណត់ ការធានារ៉ាប់រងមួយជីវិតកាល ការធានារ៉ាប់រងទាយជ្ជទាន និងការធានារ៉ាប់រងធនលាភ។

**មាត្រា៤២ .-**

អ្នកត្រូវបានធានារ៉ាប់រងឬអ្នកស្នើសុំធានារ៉ាប់រង ត្រូវកំណត់ឈ្មោះអ្នកទទួលផលនៃការធានារ៉ាប់រងអាយុជីវិតជាមុន។

អ្នកស្នើសុំធានារ៉ាប់រងត្រូវមានការយល់ព្រមជាមុនពីអ្នកត្រូវបានធានារ៉ាប់រង នៅពេលដែលអ្នកស្នើសុំធានារ៉ាប់រងនោះជាអ្នកកំណត់ឈ្មោះអ្នកទទួលផល។

**មាត្រា៤៣ .-**

អ្នកត្រូវបានធានារ៉ាប់រងឬអ្នកស្នើសុំធានារ៉ាប់រង អាចកំណត់ឈ្មោះអ្នកទទួលផលតែម្នាក់ ឬច្រើននាក់បាន។

ប្រសិនបើអ្នកទទួលផលមានច្រើននោះ អ្នកត្រូវបានធានារ៉ាប់រងឬអ្នកស្នើសុំធានារ៉ាប់រង ត្រូវកំណត់ឱ្យច្បាស់លាស់នូវលំដាប់នៃផលប្រយោជន៍និងចំណែកនៃផលប្រយោជន៍របស់អ្នកទទួលផលម្នាក់ៗ។

ប្រសិនបើចំណែកនៃផលប្រយោជន៍មិនត្រូវបានកំណត់ជាលំដាប់លំដោយ អ្នកទទួលផលទាំងអស់នឹងត្រូវទទួលបានដោយស្មើភាពគ្នា។

**មាត្រា៤៤ .-**

ចំពោះកិច្ចសន្យាធានារ៉ាប់រងអាយុជីវិត អ្នកស្នើសុំធានារ៉ាប់រងត្រូវសុំការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអ្នកត្រូវបានធានារ៉ាប់រងលើទំហំទឹកប្រាក់ធានារ៉ាប់រង បើពុំនោះទេនឹងត្រូវចាត់ទុកជាមោឃៈ។ ប៉ុន្តែ

កិច្ចសន្យាធានារ៉ាប់រងដែលរៀបចំដោយឪពុកម្ដាយសម្រាប់កូនដែលជាអនីតិជននៅក្នុងបន្ទុក មិនស្ថិតក្រោមលក្ខខណ្ឌនេះទេ។

**មាត្រា៤៥ ._**

បើគ្មានការព្រមព្រៀងជាមុនជាក់លាក់ក្នុងកិច្ចសន្យាធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត មិនត្រូវធ្វើសំណងនោះទេ នៅក្នុងករណីអ្នកត្រូវបានធានារ៉ាប់រងបានធ្វើអត្តឃាតបន្ទាប់ពីកិច្ចសន្យាធានារ៉ាប់រងត្រូវបានចូលជាធរមាន ឬអ្នកត្រូវបានធានារ៉ាប់រងត្រូវបានសម្លាប់ដោយចេតនា ឬការផ្សំគំនិតរបស់អ្នកទទួលផលណាម្នាក់។

ក្នុងករណីដែលអ្នកទទួលផលមួយឬច្រើននាក់ ជាអ្នកបង្កហេតុឱ្យស្លាប់ឬរបួសដោយចេតនាទៅលើបុគ្គលត្រូវបានធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតនៅតែត្រូវសងសំណងធានារ៉ាប់រងទៅអ្នកទទួលផលដទៃផ្សេងទៀត ដែលមិនមែនជាអ្នកបង្កហេតុទៅតាមលំដាប់នៃផលប្រយោជន៍និងចំណែកនៃផលប្រយោជន៍របស់អ្នកទទួលផលម្នាក់ៗ។ ចំពោះសំណងធានារ៉ាប់រងសម្រាប់អ្នកទទួលផលដែលបានសម្លាប់ដោយចេតនាឬផ្សំគំនិតត្រូវបង្វែរចូលមូលនិធិអភិវឌ្ឍវិស័យធានារ៉ាប់រង។

**មាត្រា៤៦ ._**

ប្រសិនបើអ្នកទទួលផលទាំងអស់ ដែលកំណត់នៅក្នុងបណ្ណសន្យារ៉ាប់រងបាត់បង់សិទ្ធិក្នុងការទទួលសំណង ហើយនាំឱ្យគ្មានអ្នកទទួលផល ទឹកប្រាក់ធានារ៉ាប់រងដែលជាអត្ថប្រយោជន៍ត្រូវចាត់ទុកជាមរតក។ ក្នុងករណីនេះ ទឹកប្រាក់ធានារ៉ាប់រងត្រូវបែងចែកទៅតាមរបបសន្តតិកម្មដែលមានចែងក្នុងក្រមរដ្ឋប្បវេណី។

**មាត្រា៤៧ ._**

ក្នុងករណីអ្នកទទួលផលជាអនីតិជន ក្រុមហ៊ុនធានារ៉ាប់រងត្រូវទូទាត់ទឹកប្រាក់ធានាជូនដល់បុគ្គលដែលមានលក្ខណសម្បត្តិតាមក្រមរដ្ឋប្បវេណីជាអាណាព្យាបាលស្របច្បាប់របស់អនីតិជននោះ។

**មាត្រា៤៨ ._**

អ្នកទទួលផលមានកាតព្វកិច្ចជូនដំណឹងអំពីការស្លាប់របស់អ្នកត្រូវបានធានារ៉ាប់រងទៅកាន់ក្រុមហ៊ុនធានារ៉ាប់រង ក្នុងអំឡុងពេលសមស្រប បន្ទាប់ពីបានដឹងអំពីការស្លាប់ តាមគ្រប់មធ្យោបាយ។

**មាត្រា៤៩ ._**

អ្នកត្រូវបានធានារ៉ាប់រងមានសិទ្ធិបោះបង់កិច្ចសន្យាធានារ៉ាប់រងអាយុជីវិតក្នុងរយៈពេលយ៉ាងតិច២១ (ម្ភៃមួយ)ថ្ងៃនៃថ្ងៃប្រតិទិន ចាប់ពីថ្ងៃចុះកិច្ចសន្យាធានារ៉ាប់រង។ ក្នុងករណីដែលមានការបោះបង់កិច្ចសន្យា

ធានារ៉ាប់រងខាងលើនេះ ក្រុមហ៊ុនមានកាតព្វកិច្ចបង្វែរបុព្វលាភធានារ៉ាប់រងទៅឱ្យអ្នកត្រូវបានធានារ៉ាប់រងវិញ ដោយដកចេញនូវចំណាយពិនិត្យសុខភាព។

**មាត្រា៥០.-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវផ្ដល់រយៈពេលអនុគ្រោះយ៉ាងតិច៣០(សាមសិប)ថ្ងៃនៃថ្ងៃប្រតិទិន សម្រាប់ការខកខានបង់បុព្វលាភធានារ៉ាប់រង ចាប់ពីថ្ងៃផុតកាលបរិច្ឆេទនៃការបង់។ ក្នុងរយៈពេលអនុគ្រោះនេះ កិច្ចសន្យាធានារ៉ាប់រងនៅតែមានសុពលភាព។ ក្នុងករណីមានហានិភ័យកើតឡើងក្នុងរយៈពេលអនុគ្រោះនេះ ក្រុមហ៊ុនធានារ៉ាប់រងត្រូវធ្វើសំណងដោយដកចេញនូវចំនួនបុព្វលាភដែលមិនទាន់បានបង់ប្រចាំគ្រា។

**មាត្រា៥១.-**

ក្នុងករណីកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតដែលមានលក្ខណៈសន្សំចូលជាធរមានបានរយៈពេល២(ពីរ) ឆ្នាំឬច្រើនជាងនេះ ក្រុមហ៊ុនធានារ៉ាប់រងមិនមានសិទ្ធិបញ្ចប់កិច្ចសន្យាធានារ៉ាប់រងភ្លាម ដោយសារការមិនបានបង់បុព្វលាភធានារ៉ាប់រងនោះទេ ប៉ុន្តែកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតអាចត្រូវបានផ្លាស់ប្ដូរលក្ខខណ្ឌឬផ្លាស់ប្ដូរអត្ថប្រយោជន៍នៃការធានារ៉ាប់រងឬផ្លាស់ប្ដូរទាំងពីរ ដោយផ្អែកតាមការកំណត់របស់ក្រុមហ៊ុនធានារ៉ាប់រងបន្ទាប់ពីការជូនដំណឹងដល់អ្នកត្រូវបានធានារ៉ាប់រង។

**មាត្រា៥២.-**

ក្នុងករណីកិច្ចសន្យាធានារ៉ាប់រងអាយុជីវិតដែលមានលក្ខណៈសន្សំចូលជាធរមាន បានរយៈពេល២(ពីរ) ឆ្នាំឬច្រើនជាងនេះ អ្នកត្រូវបានធានារ៉ាប់រងមានសិទ្ធិបញ្ចប់កិច្ចសន្យា ហើយក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្ដល់តម្លៃបោះបង់កិច្ចសន្យាជូនអ្នកត្រូវបានធានារ៉ាប់រង តាមការកំណត់នៅក្នុងកិច្ចសន្យា។

## ផ្នែកទី៤
## ការធានារ៉ាប់រងបន្ត

**មាត្រា៥៣.-**

ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិធ្វើការធានារ៉ាប់រងបន្តចេញតែប៉ុណ្ណោះ។ ក្រុមហ៊ុនធានារ៉ាប់រងបន្ត មានសិទ្ធិធ្វើទាំងការធានារ៉ាប់រងបន្តចេញនិងបន្តចូល។

**មាត្រា៥៤.-**

ក្រុមហ៊ុនធានារ៉ាប់រង មានសិទ្ធិចុះកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តចេញ ដើម្បីផ្ទេរហានិភ័យមួយផ្នែកឬទាំងស្រុង ដែលខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយអតិថិជន តែជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្តប៉ុណ្ណោះ។

ក្រុមហ៊ុនធានារ៉ាប់រងបន្ត មានសិទ្ធិចុះកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តចូល ជាមួយក្រុមហ៊ុនធានារ៉ាប់រងឬក្រុមហ៊ុនធានារ៉ាប់រងបន្តដើម្បីទទួលហានិភ័យមួយផ្នែកឬទាំងស្រុងពីក្រុមហ៊ុនធានារ៉ាប់រង។ ក្រុមហ៊ុនធានារ៉ាប់រងបន្ត មានសិទ្ធិចុះកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តចេញ តែជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្តប៉ុណ្ណោះ ដើម្បីផ្ទេរហានិភ័យមួយផ្នែកឬទាំងស្រុងពីក្រុមហ៊ុនធានារ៉ាប់រងឬក្រុមហ៊ុនធានារ៉ាប់រងបន្ត។

ទោះបីជាមានការធ្វើធានារ៉ាប់រងបន្ត ក្រុមហ៊ុនធានារ៉ាប់រងដើមនៅតែទទួលខុសត្រូវដដែល ចំពោះអ្នកត្រូវបានធានារ៉ាប់រង។

**មាត្រា៥៥.-**

រាល់កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តទាំងអស់ ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ធ.ក.** មុននឹងចុះកិច្ចព្រមព្រៀង។

គោលការណ៍ណែនាំស្តីពីការធានារ៉ាប់រងបន្ត ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

## ជំពូកទី៤

## ប្រភេទធានារ៉ាប់រងជាកាតព្វកិច្ច

### ផ្នែកទី១

### ការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត

**មាត្រា៥៦.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ជាម្ចាស់យានយន្តដែលធ្វើចរាចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវមានការធានារ៉ាប់រងយានយន្តរបស់ខ្លួនពីក្រុមហ៊ុនធានារ៉ាប់រងណាមួយលើភារៈទទួលខុសត្រូវចំពោះរាល់ការខូចខាតបង្កឡើងដល់តតិយជន។ ប្រភេទយានយន្ត ដែលត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តមានដូចខាងក្រោម៖

- យានយន្តគ្រប់ប្រភេទដែលធ្វើអាជីវកម្មដឹកជញ្ជូនទំនិញ ដឹកជញ្ជូនអ្នកដំណើរ ដឹកជញ្ជូនភ្ញៀវទេសចរ នៅព្រះរាជាណាចក្រកម្ពុជា
- យានយន្តគ្រប់ប្រភេទដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនសហគ្រាសឬរោងចក្រ
- យានយន្តគ្រប់ប្រភេទរបស់អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងសមាគមនានា
- ឧបករណ៍លាយស៊ីម៉ង់ត៍ដែលធ្វើចលនាផ្លាស់ប្តូរទីកន្លែងដោយម៉ាស៊ីនផ្ទាល់ឬដោយអូសសណ្តោង។

**មាត្រា៥៧.-**

ចំពោះបណ្ណសន្យារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ក្រុមហ៊ុនធានារ៉ាប់រងមានសិទ្ធិបដិសេធធ្វើសំណងចំពោះម្ចាស់យានយន្ត អ្នកបើកបរ អ្នកកាន់កាប់ថែទាំយានយន្ត និងអ្នករស់នៅក្នុងបន្ទុករបស់ម្ចាស់យានយន្តផ្ទាល់

ដែលបានទទួលរងរបួស ពិការឬស្លាប់ នៅក្នុងហេតុការណ៍នៃគ្រោះថ្នាក់ចរាចរណ៍។

ដើម្បីទទួលបានការធានារ៉ាប់រងចំពោះករណីដូចក្នុងកថាខណ្ឌខាងលើ ម្ចាស់យានយន្ត អ្នកបើកបរ អ្នកកាន់កាប់ថែទាំយានយន្ត និងអ្នករស់នៅក្នុងបន្ទុករបស់ម្ចាស់យានយន្តផ្ទាល់ ត្រូវមានបណ្ណសន្យារ៉ាប់រងដោយឡែកទៀត។

**មាត្រា៥៨.-**

ក្រុមហ៊ុនធានារ៉ាប់រងអាចបដិសេធធ្វើសំណងចំពោះករណីដូចខាងក្រោម៖

- អ្នកបើកបរពុំមានបណ្ណបើកបរ ឬបណ្ណបើកបរមិនមានសមិតភាពជាមួយនឹងប្រភេទយានយន្ត ឬបណ្ណបើកបរផុតសុពលភាព លើកលែងករណីដែលអនុញ្ញាតដោយច្បាប់
- អ្នកបើកបរដែលស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹង តាមកម្រិតដែលកំណត់ដោយច្បាប់ជាធរមាន
- អ្នកបើកបរដែលស្ថិតក្រោមឥទ្ធិពលនៃគ្រឿងញៀន។

**មាត្រា៥៩.-**

នីតិវិធីនៃការដោះស្រាយសំណងចំពោះការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ម.**។

**មាត្រា៦០.-**

អ្នកត្រូវបានធានារ៉ាប់រងដែលជាម្ចាស់យានយន្ត ឬអ្នកបើកបរ ឬអ្នកកាន់កាប់ថែទាំយានយន្តត្រូវបង្ហាញវិញ្ញាបនបត្រធានារ៉ាប់រងដល់អាជ្ញាធរមានសមត្ថកិច្ច ប្រសិនបើមានតម្រូវការចាំបាច់។

**មាត្រា៦១.-**

អ្នកត្រូវបានធានារ៉ាប់រងដែលជាម្ចាស់យានយន្ត ត្រូវបិទលតាបត្រតាមប្រកាសរបស់ប្រធាន**អ.ស.ម.**។

## ផ្នែកទី២

## ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន

**មាត្រា៦២.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ជាម្ចាស់ការដ្ឋាន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្ត ដែលធ្វើការសាងសង់ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានចំពោះគ្រោះថ្នាក់ទាំងឡាយ ទោះបីដល់រូបរាងកាយក្តីឬទ្រព្យសម្បត្តិក្តីរបស់តតិយជនទាំងឡាយដែលរស់នៅក្នុង ឬជុំវិញការដ្ឋាន ឬធ្វើដំណើរឆ្លងកាត់ ឬ

ក្បែរការដ្ឋាន ដែលត្រូវបានបង្កឡើងដោយសកម្មភាពរបស់ការដ្ឋាន។

**មាត្រា៦៣.-**

ប្រភេទការដ្ឋានដែលចាំបាច់ត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន រួមមានការដ្ឋានសាងសង់ ការដ្ឋានជួសជុល និងការដ្ឋានដំឡើងទាំងអស់ដែលទទួលខុសត្រូវដោយសហគ្រិន អ្នកម៉ៅការ ឬអ្នកម៉ៅការបន្ត លើកលែងតែនីតិបុគ្គលនៃនីតិសាធារណៈ ដែលទទួលបន្ទុកការងារសាងសង់ ជួសជុល ឬដំឡើងដើម្បីជាផលប្រយោជន៍សាធារណៈ។ ការសាងសង់ឬជួសជុលកែលម្អតូចតាចដែលមិនតម្រូវឱ្យមានការអនុម័តលើគម្រោងប្លង់ពីស្ថាប័នមានសមត្ថកិច្ច ក៏ត្រូវបានលើកលែងផងដែរ។

## ផ្នែកទី៣
## ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដឹកជញ្ជូនអ្នកដំណើរ

**មាត្រា៦៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គល ជាម្ចាស់មធ្យោបាយដឹកជញ្ជូនអ្នកដំណើរគ្រប់ប្រភេទ ដែលមានលិខិតអនុញ្ញាតឱ្យប្រកបអាជីវកម្មដឹកជញ្ជូនអ្នកដំណើរក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដឹកជញ្ជូនអ្នកដំណើរ ចំពោះអ្នកដំណើររបស់ខ្លួន។

# ជំពូកទី៥
# គ្រឹះស្ថានធានារ៉ាប់រងនិងការផ្តល់អាជ្ញាបណ្ណ
## ផ្នែកទី១ នីតិវិធី និងលក្ខខណ្ឌនៃការផ្តល់អាជ្ញាបណ្ណ
### ១- ក្រុមហ៊ុនធានារ៉ាប់រង

**មាត្រា៦៥.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មធានារ៉ាប់រងជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ដែលបានចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនធានារ៉ាប់រងមក**ន.ធ.ក**.តាមលក្ខខណ្ឌគោលដូចខាងក្រោម៖

- ជានីតិបុគ្គលប្រតិស្រុត
- ក្នុងទម្រង់ទ្រាយជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត
- មានសមាសភាពភាគទុនិកយ៉ាងតិច២(ពីរ)រូបចំពោះសមាសភាពភាគទុនិកដែលជារូបវន្តបុគ្គលទាំងអស់
- មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់តាមច្បាប់ស្តីពីការធានារ៉ាប់រង
- មានជំនាញវិជ្ជាជីវៈធានារ៉ាប់រង។

នីតិវិធីនិងលក្ខខណ្ឌតម្រូវលម្អិតនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ធ.**។

**មាត្រា៦៦.-**

អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនធានារ៉ាប់រងមានបីប្រភេទ៖

១- អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនធានារ៉ាប់រងទូទៅ។

២- អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត។

៣- អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនធានារ៉ាប់រងបន្ត។

## ២- ជើងសាធានារ៉ាប់រង

**មាត្រា៦៧.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មជើងសាធានារ៉ាប់រងជាប្រភេទក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ដែលបានចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនជើងសាធានារ៉ាប់រងមក**ន.ធ.ក.** តាមលក្ខខណ្ឌគោលដូចខាងក្រោម៖

- ជានីតិបុគ្គលប្រតិស្រុត
- មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់តាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការធានារ៉ាប់រង
- មានជំនាញវិជ្ជាជីវៈជើងសាធានារ៉ាប់រង។

នីតិវិធីនិងលក្ខខណ្ឌតម្រូវលម្អិតនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនជើងសាធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ធ.**។

**មាត្រា៦៨.-**

អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនជើងសាធានារ៉ាប់រងមានបីប្រភេទ៖

១- អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនជើងសាធានារ៉ាប់រងទូទៅ។

២- អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនជើងសាធានារ៉ាប់រងអាយុជីវិត។

៣- អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនជើងសាធានារ៉ាប់រងបន្ត។

## ៣- ភ្នាក់ងារធានារ៉ាប់រង

**មាត្រា៦៩.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រងជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ដែលបាន

ចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនភ្នាក់ងារធានា-រ៉ាប់រងមក**ន.ធ.ក.** តាមលក្ខខណ្ឌគោលដូចខាងក្រោម៖

- ជានីតិបុគ្គលប្រតិស្រុត
- មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់តាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការធានារ៉ាប់រង
- មានជំនាញវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង។

នីតិវិធីនិងលក្ខខណ្ឌតម្រូវលម្អិតនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

**មាត្រា៧០.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល ត្រូវចុះបញ្ជីប្រកបវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងនៅ**ន.ធ.ក.**។

នីតិវិធីនិងលក្ខខណ្ឌតម្រូវលម្អិតនៃការចុះបញ្ជីប្រកបវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

## ៤- ក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង

**មាត្រា៧១.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រងជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេសដែលបានចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រងមក**ន.ធ.ក.** តាមលក្ខខណ្ឌគោលដូចខាងក្រោម៖

- ជានីតិបុគ្គលប្រតិស្រុត
- មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់តាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការធានារ៉ាប់រង
- មានជំនាញវិជ្ជាជីវៈវាយតម្លៃហានិភ័យធានារ៉ាប់រង។

នីតិវិធីនិងលក្ខខណ្ឌតម្រូវលម្អិតនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មវាយតម្លៃហានិភ័យធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

## ៥- ក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង

**មាត្រា៧២.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មគណនាបុព្វលាភធានារ៉ាប់រងជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេសដែលបានចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុន

គណនាបុព្វលាភធានារ៉ាប់រងមក**ន.ធ.ក.** តាមលក្ខខណ្ឌគោលដូចខាងក្រោម៖

- ជានីតិបុគ្គលប្រតិស្រុត
- មានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់តាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការធានារ៉ាប់រង
- មានជំនាញវិជ្ជាជីវៈគណនាបុព្វលាភធានារ៉ាប់រង។

នីតិវិធីនិងលក្ខខណ្ឌតម្រូវលម្អិតនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

## ផ្នែកទី២
## អភិបាលកិច្ចគ្រឹះស្ថានធានារ៉ាប់រង

**មាត្រា៧៣.-**

រាល់ការតែងតាំងឬផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាភិបាលឬគណៈគ្រប់គ្រងរបស់គ្រឹះស្ថានធានារ៉ាប់រងទាំងអស់ ត្រូវមានការអនុញ្ញាតជាមុនពី**ន.ធ.ក.**។

**មាត្រា៧៤.-**

បុគ្គលដែលជាសមាជិកក្រុមប្រឹក្សាភិបាលឬគណៈគ្រប់គ្រងរបស់គ្រឹះស្ថានធានារ៉ាប់រងត្រូវមានគុណវុឌ្ឍិស្របតាមលក្ខណៈវិនិច្ឆ័យ*“សមស្រប”*រួមដូចខាងក្រោម៖

១. សុចរិតភាព សមត្ថភាព និងសុភវិនិច្ឆ័យក្នុងការបំពេញភារកិច្ចនិងការទទួលខុសត្រូវលើមុខតំណែង

២. ការយកចិត្តទុកដាក់ក្នុងការបំពេញភារកិច្ច

៣. លក្ខណៈវិនិច្ឆ័យជាបុគ្គលដែលមិនធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ម្ចាស់បណ្ណសន្យារ៉ាប់រង អ្នកទាមទារសំណងធានារ៉ាប់រង អតិថិជន និងឥណទាយករបស់ក្រុមហ៊ុនធានារ៉ាប់រង។

លក្ខណៈវិនិច្ឆ័យដោយឡែករបស់សមាជិកក្រុមប្រឹក្សាភិបាលនិងគណៈគ្រប់គ្រងគ្រឹះស្ថានធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

**មាត្រា៧៥.-**

ក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែងតាំងអ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រងដែលមានវិជ្ជាជីវៈ ដោយមានការអនុញ្ញាតជាមុនពី**ន.ធ.ក.**។

គុណវុឌ្ឍិ មុខងារ និងតួនាទីរបស់អ្នកជំនាញគណនាបុព្វលាភធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

## ផ្នែកទី៣
## ការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានធានារ៉ាប់រង

**មាត្រា៧៦ ._**

គ្រឹះស្ថានធានារ៉ាប់រង មានកាតព្វកិច្ចរក្សាទំហំដើមទុនអប្បបរមាក្នុងអំឡុងពេលនៃដំណើរការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីដែលទឹកប្រាក់នៃដើមទុនអប្បបរមានេះ ត្រូវបានប្រើប្រាស់នៅសល់ក្រោមកម្រិតកំណត់ ក្រុមហ៊ុនត្រូវបំពេញបង្គ្រប់វិញ។

ដើមទុនអប្បបរមារបស់គ្រឹះស្ថានធានារ៉ាប់រងអាចតម្រូវឱ្យបង្កើន តាមការកំណត់របស់ប្រធាន**អ.ស.ធ.**។

**មាត្រា៧៧ ._**

ក្រុមហ៊ុនធានារ៉ាប់រងត្រូវមានដើមទុនអប្បបរមាជាប្រាក់រៀល ដែលអត្រាសមមូលនឹង៥ ០០០ ០០០ (ប្រាំលាន) អេសឌីអ័រ តាមអត្រាពេលចេញអាជ្ញាបណ្ណ។

**មាត្រា៧៨ ._**

ដើមទុនអប្បបរមាដែលតម្រូវសម្រាប់អាជីវកម្មក្រុមហ៊ុនជើងសាធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ធ.**។ ដើមទុនអប្បបរមា មិនត្រូវស្ថិតក្រោមចំនួន៤០០ ០០០ ០០០(បួនរយលាន)រៀល។

**មាត្រា៧៩ ._**

ដើមទុនអប្បបរមាដែលតម្រូវសម្រាប់អាជីវកម្មក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ធ.**។ ដើមទុនអប្បបរមា មិនត្រូវស្ថិតក្រោមចំនួន៨០ ០០០ ០០០(ប៉ែតសិបលាន)រៀល។

**មាត្រា៨០ ._**

ដើមទុនអប្បបរមាដែលតម្រូវសម្រាប់អាជីវកម្មក្រុមហ៊ុនវាយតម្លៃហានិភ័យធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ធ.**។ ដើមទុនអប្បបរមា មិនត្រូវស្ថិតក្រោមចំនួន៨០ ០០០ ០០០(ប៉ែតសិបលាន)រៀល។

**មាត្រា៨១ ._**

ដើមទុនអប្បបរមាដែលតម្រូវសម្រាប់អាជីវកម្មក្រុមហ៊ុនគណនាបុព្វលាភធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ធ.**។ ដើមទុនអប្បបរមា មិនត្រូវស្ថិតក្រោមចំនួន៨០ ០០០ ០០០(ប៉ែតសិបលាន)រៀល។

**មាត្រា៨២ ._**

លក្ខខណ្ឌតម្រូវនៃការកំណត់ដើមទុនអប្បបរមានិងកម្រិតសាធនភាពរបស់គ្រឹះស្ថានធានារ៉ាប់រង ត្រូវកំណត់

ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

**មាត្រា៨៣.-**

ក្រុមហ៊ុនធានារ៉ាប់រង អាចធ្វើការវិនិយោគនូវមូលនិធិដែលលើសពីដើមទុនអប្បបរមា។ គោលការណ៍វិនិយោគនេះ ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

**មាត្រា៨៤.-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវបង្កើតឱ្យមានគណៈកម្មាធិការវិនិយោគដែលជាអនុគណៈកម្មាធិការនៃក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។ សមាសភាពនិងតួនាទីរបស់គណៈកម្មាធិការនេះ ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

**មាត្រា៨៥.-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវរក្សាប្រាក់បម្រុងធានារ៉ាប់រងដើម្បីធានាកាតព្វកិច្ចធានារ៉ាប់រង។ គោលការណ៍ណែនាំស្ដីពីការគណនាប្រាក់បម្រុង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

**មាត្រា៨៦.-**

ក្នុងអំឡុងពេល៣(បី)ខែ ក្រោយពេលបញ្ចប់ឆ្នាំហិរញ្ញវត្ថុឬក្នុងអំឡុងពេលបន្ថែមណាមួយដែលបានទទួលការអនុញ្ញាតពី**ន.ធ.ភ.** ក្រុមហ៊ុនធានារ៉ាប់រងត្រូវផ្ដល់មក**ន.ធ.ភ.**នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវបានធ្វើសវនកម្មរួចហើយដោយសវនករដែលមានអាជ្ញាបណ្ណពីនិយ័តករគណនេយ្យនិងសវនកម្ម។ របាយការណ៍នេះត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់ស្ដីពីគណនេយ្យនិងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**មាត្រា៨៧.-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងទម្រង់មួយតាមការតម្រូវរបស់**ន.ធ.ភ.**។

**មាត្រា៨៨.-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវស្នើសុំការអនុញ្ញាតជាមុនពី**ន.ធ.ភ.** ចំពោះការជ្រើសរើសក្រុមហ៊ុនសវនកម្ម។ មានតែក្រុមហ៊ុនសវនកម្មដែលបានចុះបញ្ជីជាមួយ**ន.ធ.ភ.**ទេ ដែលអាចអនុញ្ញាតឱ្យធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានធានារ៉ាប់រងបាន។

នីតិវិធីនិងគោលការណ៍កំណត់សម្រាប់ចុះបញ្ជីក្រុមហ៊ុនសវនកម្ម ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

**មាត្រា៨៩.-**

គ្រឹះស្ថានធានារ៉ាប់រង ត្រូវផ្តល់ជូន**ន.ធ.ភ.** នូវរបាយការណ៍ហិរញ្ញវត្ថុមុនធ្វើសវនកម្ម ជាប្រចាំត្រីមាសនិងប្រចាំឆ្នាំ។ របាយការណ៍ហិរញ្ញវត្ថុទាំងនោះរួមមានដូចខាងក្រោម៖

- តារាងតុល្យការ
- របាយការណ៍ចំណេញ-ខាតនិងរបាយការណ៍ចំណូលផ្សេងៗ
- របាយការណ៍មូលនិធិម្ចាស់ហ៊ុន
- របាយការណ៍លំហូរសាច់ប្រាក់
- កំណត់សម្គាល់របស់របាយការណ៍ហិរញ្ញវត្ថុ។

ក្រៅពីនេះ គ្រឹះស្ថានធានារ៉ាប់រងត្រូវផ្តល់ជូន**ន.ធ.ភ.** នូវរបាយការណ៍ផ្សេងទៀតតាមការចាំបាច់។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបញ្ជាក់អះអាងថាត្រឹមត្រូវនិងត្រូវផ្តល់ជូន**ន.ធ.ភ.** ជាលាយលក្ខណ៍អក្សរ ឬតាមរយៈសារអេឡិចត្រូនិក។ គ្រឹះស្ថានធានារ៉ាប់រងត្រូវផ្តល់របាយការណ៍នេះ ក្នុងទម្រង់មួយតាមការតម្រូវរបស់**ន.ធ.ភ.**។

**មាត្រា៩០.-**

គ្រឹះស្ថានធានារ៉ាប់រងត្រូវផ្តល់ជូន**ន.ធ.ភ.**នូវរបាយការណ៍ប្រចាំខែក្នុងទម្រង់មួយតាមការតម្រូវរបស់**ន.ធ.ភ.**។

**មាត្រា៩១.-**

គ្រឹះស្ថានធានារ៉ាប់រងមានកាតព្វកិច្ចអនុវត្តច្បាប់និងបទប្បញ្ញត្តិជាធរមាន ស្តីពីការប្រឆាំងការលាងសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ និងច្បាប់ និងបទប្បញ្ញត្តិជាធរមានស្តីពីអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេស។

## ជំពូកទី៦
## អធិការកិច្ចធានារ៉ាប់រង

**មាត្រា៩២.-**

មន្ត្រីអធិការកិច្ចធានារ៉ាប់រង ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់ស្តីពីការធានារ៉ាប់រង ដោយអនុវត្តឱ្យស្របទៅតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ចំពោះមន្ត្រីអធិការកិច្ចធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធាន**អ.ស.ហ.**។

**មាត្រា៩៣.-**

ការចុះអធិការកិច្ចធានារ៉ាប់រងនឹងប្រព្រឹត្តទៅជាប្រចាំឬដោយមិនចាំបាច់ជូនដំណឹងជាមុន តាមឆន្ទានុសិទ្ធិរបស់ប្រធាន**អ.ស.ហ.**។

**មាត្រា៩៤.-**

នីតិវិធីអធិការកិច្ចធានារ៉ាប់រង ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ហ.**។

## ជំពូកទី៧

## ការផ្សះផ្សាវិវាទ

**មាត្រា៩៥.-**

ចំពោះគ្រប់វិវាទដែលពាក់ព័ន្ធនឹងអាជីវកម្មធានារ៉ាប់រង ភាគីណាមួយនៃភាគីវិវាទអាចនាំយកវិវាទទៅជូន**ន.ធ.ក.** ដើម្បីសម្រុះសម្រួលធ្វើការផ្សះផ្សាវិវាទមុននឹងប្តឹងទៅវេទិកាមជ្ឈត្តកម្មឬតុលាការមានសមត្ថកិច្ចលើកលែងតែរឿងព្រហ្មទណ្ឌ។

**មាត្រា៩៦.-**

បុគ្គលទាំងឡាយណាដែលមានវិវាទធានារ៉ាប់រងជាមួយគ្រឹះស្ថានធានារ៉ាប់រង មានសិទ្ធិធ្វើបណ្តឹងវិវាទធានារ៉ាប់រងទៅគ្រឹះស្ថានធានារ៉ាប់រងដើម្បីដោះស្រាយឬមក**ន.ធ.ក.** ដើម្បីផ្សះផ្សាឱ្យសះជា។

**មាត្រា៩៧.-**

**ន.ធ.ក.** ត្រូវចាត់តាំងមន្ត្រីទទួលពាក្យបណ្តឹងវិវាទធានារ៉ាប់រង។

**មាត្រា៩៨.-**

អ្នករងការប្តឹងត្រូវឆ្លើយតបដោយការបំភ្លឺ ក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានដីកាបញ្ជូនពាក្យបណ្តឹងពី**ន.ធ.ក.**។

**មាត្រា៩៩.-**

រាល់ការសាកសួរព័ត៌មាននិងការប្រជុំផ្សះផ្សាវិវាទ នៅក្នុងដំណើរការបណ្តឹង ត្រូវធ្វើឡើងនៅ**ន.ធ.ក.**។

**មាត្រា១០០.-**

**ន.ធ.ក.** ត្រូវបញ្ចប់នីតិវិធីដំណើរការបណ្តឹង ក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យបណ្តឹង។ ក្នុងករណីដែលភាគីវិវាទមិនសះជា ភាគីវិវាទអាចជ្រើសរើសនីតិវិធីបន្តដូចមានចែងក្នុងមាត្រា៩២ នៃច្បាប់ស្តីពីការធានារ៉ាប់រង។

**មាត្រា១០១ .-**

នីតិវិធីលម្អិតនៃការផ្សះផ្សាវិវាទ ត្រូវកំណត់ដោយប្រកាសរបស់ប្រធាន**អ.ស.ធ.**។

## ជំពូកទី៨
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១០២ .-**

រូបវន្តបុគ្គលឬនីតិបុគ្គល ជាអ្នកត្រូវបានធានារ៉ាប់រង អាចចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងក្រៅស្រុកបាន តែចំពោះការធានារ៉ាប់រងលើហានិភ័យនៃការដឹកជញ្ជូនទំនិញជាអន្តរជាតិតាមផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា១០៣ .-**

អាជ្ញាបណ្ណធានារ៉ាប់រង វិញ្ញាបនបត្រ និងលិខិតអនុញ្ញាត ដែលបានផ្តល់ជូនគ្រឹះស្ថានធានារ៉ាប់រងទាំងអស់ អនុលោមតាមអនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១ ត្រូវបន្តសុពលភាពរហូតដល់ផុតកាលកំណត់នៃអាជ្ញាបណ្ណធានារ៉ាប់រង វិញ្ញាបនបត្រ និងលិខិតអនុញ្ញាតទាំងនោះ។

## ជំពូកទី១០
## អវសានប្បញ្ញត្តិ

**មាត្រា១០៤ .-**

អនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១ ត្រូវបាត់បង់អានុភាពអនុវត្តចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

បទដ្ឋានគតិយុត្តក្រោមអនុក្រឹត្យលេខ១០៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០១ ត្រូវបន្តអានុភាពអនុវត្តរហូតមានបទដ្ឋានថ្មីមកជំនួស លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃអនុក្រឹត្យនេះ។

**មាត្រា១០៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១១រោចខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ